

# ការជំរុញទឹកចិត្តអ្នកដឹកនាំ

"ធ្វើជាប្រធានគណៈកម្មការ អាចឲ្យខ្ញុំជាស្ត្រីបានចូលរួមក្នុងការងារសង្គមបានច្រើនតឹយើងហ៊ានប្រឡូកនៅក្នុងសង្គម" ។

អ្នកស្រី ញឹក ប៉ូលី ជាប្រធានគណៈកម្មការសម្របសម្រួលការដោះស្រាយវិវាទដើម្បីយុត្តិធម៌សម្រាប់ជនក្រីក្រ (AJC) និងជាសមាជិកក្រុមប្រឹក្សាប្រចាំឃុំថ្មី ខេត្តក្រចេះ ។

មុនពេលដែលអ្នកស្រីត្រូវបានបោះឆ្នោតជ្រើសតាំងជាប្រធានគណៈកម្មការ អ្នកស្រី ប៉ូលី ដែលមានកូនបីនាក់ បានប្រកបការងារជាកសិករលើដីបន្តិចបន្តួចដើម្បីផ្គត់ផ្គង់គ្រួសារ ។ អ្នកស្រី បានថ្លែងថា អ្នកស្រីធ្លាប់ខ្វះទំនុកចិត្តក្នុងការនិយាយស្តី ជាសាធារណៈ និងនៅចំពោះបុគ្គលសំខាន់ៗ និងមានឋានៈធំ ។

តាមរយៈតួនាទីរបស់គាត់ក្នុងនាមជាប្រធានគណៈកម្មការឃុំ អ្នកស្រីប៉ូលី បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ ដើម្បីអភិវឌ្ឍការយល់ដឹងរបស់គាត់ ខាងផ្នែកច្បាប់ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធ ក៏ដូចជាជំនាញស្វែងរកការគាំទ្រមតិ និងភាពជាអ្នកដឹកនាំជាដើម ។ ជាមួយនឹងជំនាញថ្មីទាំងអស់នេះ អ្នកស្រីបានក្លាយជាមេដឹកនាំដែលទទួលបានការគោរពខ្ពស់ ហើយមានឥទ្ធិពលក្នុងការគ្រប់គ្រងសហគមន៍របស់ខ្លួន ។

"ពីមុនអត់ហ៊ានទេ ។ ពេលឃើញគេប្លែកៗក្បាលពោះធំៗ គឺភ័យញ័រខ្លាចគេ"។ ទោះជាយ៉ាងណា នៅដើមឆ្នាំ ២០១៣ អ្វីៗចាប់ផ្តើមផ្លាស់ប្តូរ នៅពេលដែលអ្នកស្រីត្រូវបានបោះឆ្នោតជ្រើសតាំងជាប្រធានគណៈកម្មការ ។

"ខ្ញុំហាក់ដូចជាភ័យផង! អរផង! ។ អរត្រង់ថា ខ្ញុំមានមោទនភាព ដែលប្រជាពលរដ្ឋក្នុងសហគមន៍ ទុកចិត្តខ្ញុំ ដោយបានបោះឆ្នោតគាំទ្រខ្ញុំ។ អារម្មណ៍ភ័យនោះ គឺត្រង់ថាពេលដែលយើងជាប់ឆ្នោតហើយ មិនដឹងថាយើងគ្រប់គ្រងការងារបានឬអត់ហើយ តើការងារនោះត្រូវធ្វើរបៀបម៉េចដើម្បីឆ្លើយតបទៅនឹងទំនុកចិត្តដែលគេបោះឆ្នោតគាំទ្រខ្ញុំ" ។

អ្នកស្រីប៉ូលី បានបញ្ជាក់ថា អ្នកស្រីបានរៀនចេះដឹងច្រើន ចាប់តាំងពីចូលបម្រើការងារនេះមក ហើយអ្នកស្រីសង្ឃឹមថា ស្ត្រីផ្សេងទៀត នឹងយកគំរូតាម និងមានទំនុកចិត្តក្នុងការអនុវត្តតួនាទីកាន់តែសកម្មជាងមុននៅក្នុងសហគមន៍របស់ខ្លួន ។

"ខ្ញុំស្នើឲ្យស្ត្រីៗយើង លះបង់ពេលវេលាខ្លះ ដើម្បីចូលរួមការងារសង្គមបើទោះបីជាមានប្តីហើយក៏ដោយឃ្មុំ" ។



# ការដោះស្រាយបញ្ហា

លោក រស់ មាន់ ជាមេភូមិស្រែឆ្នង់ ក្នុងខេត្តព្រះវិហារ អស់រយៈពេលជាង ១០ ឆ្នាំមកហើយ ។ លោកបាននិយាយថា លោកតែងជួបការលំបាកក្នុងការដោះស្រាយវិវាទនៅក្នុងសហគមន៍ដ៏ដាច់ស្រយ៉ាលរបស់គាត់ ដែលមានប្រជាជនភាគច្រើនជាជនជាតិភាគតិចគួយ ។ នេះក៏ដោយសារតែកង្វះការយល់ដឹងពីច្បាប់ និងកង្វះយន្តការរឹងមាំក្នុងការដោះស្រាយវិវាទ ។

"ពេលហៅមកដោះស្រាយបញ្ហាម្តងៗ ដូចជាតឹងសរសៃកបន្តិច" ។

ស្ថានភាពបែបនេះបានផ្លាស់ប្តូរ បន្ទាប់ពីមានការបង្កើតគណៈកម្មការសម្របសម្រួល ការដោះស្រាយវិវាទដើម្បីយុត្តិធម៌សម្រាប់ជនក្រីក្រ (AJC) នៅក្នុងតំបន់នោះ ។ គណៈកម្មការនេះបានផ្តល់ជាវេទិកាសម្រាប់ប្រជាពលរដ្ឋនិយាយចេញអំពីបញ្ហារបស់ពួកគាត់ និងដោះស្រាយវិវាទមុនពេលដែលវិវាទកាន់តែធ្ងន់ធ្ងរ ។

"បទពិសោធន៍ល្អៗដែលយើងទទួលបានពីគណៈកម្មការAJC គឺថាពេលណាមានទំនាស់ប្រជាពលរដ្ឋម្តងៗ គាត់ជួយឲ្យមតិល្អៗដល់ភាគីទំនាស់ហ្នឹង ជៀសវាងកុំឲ្យរឿងទៅដល់ឃុំឬស្រុក...គឺដោះស្រាយនៅភូមិយើងតែម្តង" ។

លោក រស់ មាន់បានថ្លែងថា គណៈកម្មការនេះបានជួយឲ្យគាត់កសាងទំនាក់ទំនងកាន់តែជិតស្និទ្ធជាងមុនជាមួយនឹងប្រជាពលរដ្ឋនៅក្នុងសហគមន៍ ដូច្នេះហើយបានជាការដោះស្រាយវិវាទកាន់តែងាយស្រួលជាងមុន ។ សមាជិករបស់គណៈកម្មការ គឺលោក អាន លឿន ដែលបានធ្វើការងារនៅក្នុងឃុំស្រែឆ្នង់ចាប់តាំងពីឆ្នាំ ២០១៣ បានថ្លែងថា លោកបានកត់សម្គាល់ពីការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ជុំវិញកម្រិតនៃការយល់ដឹងរបស់អ្នកភូមិទាក់ទងនឹងការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ ។

"ក្នុងនាមជាផ្នែកមួយនៃគណៈកម្មការ ខ្ញុំបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋនូវព័ត៌មានទាក់ទងនឹងការគ្រប់គ្រងដីធ្លី និងសិទ្ធិ។ កាលពីដើមឡើយ យើងអត់ដឹងអីទាំងអស់!គាត់ចេះតែដើរចង្អុលថា អានេះដីខ្ញុំ អានោះដីខ្ញុំ"" ។



# កម្មវិធីអភិបាលកិច្ច ធនធានធម្មជាតិ នៃ អង្គការអុកស្វាម



# រៀនដើម្បីជួយ

នៅដើមឆ្នាំ ២០១៥ មានអ្នកភូមិជាមួយគ្នាម្នាក់មកអះអាងថា ជាម្ចាស់កម្មសិទ្ធិលើដីរបស់លោក ខ្វែង លីម ដែលជាកសិករមួយរូប ។ នៅពេលនោះ លោកមិនដឹងថាតើត្រូវទៅរកនរណាឲ្យជួយនោះទេ ។ ប៉ុន្តែ នៅពេលដែលគណៈកម្មការសម្របសម្រួលការដោះស្រាយវិវាទដើម្បីយុត្តិធម៌សម្រាប់ជនក្រីក្រ (AJC) ថ្នាក់ឃុំបានចុះមកជួយសម្របសម្រួល លោកក៏ចាប់ផ្តើមមើលឃើញពីលទ្ធផលភ្លាម ។

"បើមានសាច់ញាតិ ឬអ្នកជិតខាងមានបញ្ហាស្រដៀងៗខ្ញុំ ខ្ញុំអាចណែនាំគេឲ្យទៅ...AJC" ។

"ដីហ្នឹង ខ្ញុំដោះ៣លើកៗ ដោះ២លើកនៅភូមិ អត់បានសម្រេចៗ រំលងមួយអាទិត្យមកក៏មានគណៈកម្មការAJCមកជួយ ទើបបានសម្រេចទៅ" ។

នៅពេលនេះ លោក លីម មានការយល់ដឹងច្រើនជាងមុនទាក់ទងនឹងច្បាប់ដីធ្លីក៏ដូចជាសិទ្ធិ និងការទទួលខុសត្រូវរបស់គាត់ ។ ដូច្នេះ លោកកាន់តែមានទំនុកចិត្តជាងមុនក្នុងការស្វះស្វែងរកស្ថាប័នណាមួយមកជួយដល់រូបលោក និងអ្នកផ្សេងទៀត ប្រសិនបើមានករណីវិវាទកើតឡើងនៅថ្ងៃក្រោយ ។

តទៅមុខទៀត ខ្ញុំក៏ចង់ធ្វើជាគណៈកម្មការ AJCហ្នឹងដែរ ហើយជួយដោះស្រាយបញ្ហាឲ្យបានល្អជាងហ្នឹងទៀត"។

នៅពេលសួរថាតើលោកចង់ឲ្យមាន គណៈកម្មការ AJC នៅក្នុងសហគមន៍របស់គាត់រហូតដល់ពេលណា លោកបានឆ្លើយភ្លាមថា ៖ "

"អូ! ចង់ឲ្យមានជារៀងរហូតហ្នឹង" ។

## គម្រោង ពង្រឹងភាពជាដៃគូឆ្ពោះទៅរកការចូលរួម និងគណនេយ្យភាពក្នុងអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា

អង្គការអុកស្វាមមានជំនឿថា ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិប្រកបដោយយុត្តិធម៌ និងនិរន្តរភាព គឺមានសារសំខាន់ចំពោះការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ។ ដើម្បីធានាថា ដំណើរការនេះមានតម្លាភាព និងគណនេយ្យភាពវាជាកិច្ចសំខាន់ដែលមនុស្សគ្រប់គ្នានៅក្នុងសង្គម រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្របំផុត និងជួបការលំបាកបំផុត អាចចូលរួមនៅក្នុងការងារអភិបាលកិច្ចលើដីធ្លីរបស់ពួកគាត់ ។

ដោយមានការគាំទ្រ និងជំនួយពីសហភាពអឺរ៉ុប ដូច្នេះហើយបានជាអង្គការអុកស្វាម បានចាប់ផ្តើមអនុវត្តគម្រោងក្នុងទំហំទឹកប្រាក់ជិត ១ លានអឺរ៉ូ កាលពីខែមករា ឆ្នាំ ២០១៣ ដោយផ្តោតលើភូមិចំនួន ២៤០ នៅក្នុងខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ និងស្ទឹងត្រែង ។ វត្ថុបំណងសំខាន់គឺកសាងភាពជាដៃគូរឹងមាំជាងមុនរវាងអាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍ដែលខ្លួនធ្វើការបម្រើ ។ គម្រោងនេះបានជួយគាំទ្រដល់ការបង្កើត គណៈកម្មការសម្របសម្រួលការដោះស្រាយវិវាទដើម្បីយុត្តិធម៌ សម្រាប់ជនក្រីក្រ (AJC) ក៏ដូចជាបណ្តាញសកម្មភាពការពារដីធ្លី និងបរិស្ថានកម្ពុជា (CLEAN) នៅថ្នាក់ខេត្ត ។ គណៈកម្មការទាំងនេះបានផ្តល់ជាវេទិកាសម្រាប់សហគមន៍ និងក្រុមអង្គការសង្គមស៊ីវិល អាចទាក់ទងធ្វើការងារជាមួយនឹងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាផ្តល់ឱកាសក្នុងការចែករំលែកជំនាញ និងកសាងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍នៅបរទេស ។

ដោយសហការជាដៃគូយ៉ាងជិតស្និទ្ធជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៥អង្គការអុកស្វាមបានជួយគាំទ្រដល់ការងារចែករំលែកព័ត៌មាន និងកិច្ចពិភាក្សាលើគោលនយោបាយ ក្នុងចំណោមគណៈកម្មការដែលជួយផ្តល់ភាពអង់អាចដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការស្វែងរកការគាំទ្រមតិឲ្យមានអភិបាលកិច្ចធនធានធម្មជាតិ និងដីធ្លីប្រកបដោយនិរន្តរភាព ។

ឧបត្ថម្ភដោយ

សហភាពអឺរ៉ុប

OXFAM

ដៃគូសហការ



# INSPIRING LEADERS

***"Being elected head of the committee has allowed me to get involved in a lot of social work, and I now have the confidence to play a bigger role in society"***

Nhiek Boly is head of the Access to Justice Committee (AJC) and a commune councilor in Thmey commune in Kratie province.

Before she was elected to lead the committee Boly, a mother of three, farmed her smallholding to support her family. She says she lacked the confidence to speak up in public and in front of important and powerful people.

In her new role as head of the AJC committee, Boly has taken part in training sessions and exchange visits to develop her understanding of the law and alternative dispute resolution methods as well as her advocacy and leadership skills. Armed with these new abilities, she has become a highly respected leader with a strong voice in the running of her community.

***"I was so scared before. Every time I met a stranger or someone with a big belly, I was always nervous"***

However, everything started to change in 2013 when she was elected to head the AJC.

***"I had mixed feelings at the time. I was excited that the community trusted me enough to choose me as head of the committee. But I was worried about the workload. I didn't know how I would handle it or how I would be able to give back to those who voted for me"***

Boly says she has learned a lot since taking up the position and she hopes other women will follow her example and gain the confidence to play a more active role in their communities.

***"I would encourage all women, even those who are married, to devote some of their time to working in the community"***

# SOLVING PROBLEMS



Ros Moan has been chief of Srae Thnong village in Preah Vihear province for more than 10 years. He says it was often difficult to solve disputes in his remote community, which includes many members from the Kuoy ethnic minority, due to a lack of knowledge about legislation and the absence of an established dispute resolution mechanism.

***"When we tried solving disputes in the past, it often led to tense situations"***

The situation changed after an Access to Justice Committee for the Poor (AJC) was set up in the area. This gave the villagers a platform to talk about their problems, and to solve disputes before they escalate.

***"The committee always gives good advice to people with disputes, and encourages them to avoid escalating the problem and to solve it here in the village"***

Mr. Moan says the committee helped him build stronger relationships with the people in his community, which in turn made dispute resolution easier.

Committee member Arn Loeun, who has been working in Srae Thnong village since 2013, said he has noticed a remarkable change in the villagers' level of awareness about land and natural resource management.

***"[As part of the committee] I have helped disseminate a lot of information about land management and rights. In the past, we knew nothing. To identify their land, people would just point at it and say it's their land"***



# LEARNING TO HELP

When a neighbor claimed ownership over Klaeng Lim's land in early 2015, the farmer had no idea where to turn for help. It was not until the commune Access to Justice Committee for the Poor (AJC) began to mediate that he started to see results.

***"If my relatives or neighbors have a similar problem to mine, I'll tell them to ask for help from the AJC"***

***"We tried solving the dispute 3 times. Twice at the village level, we were not successful. One week after that, the committee helped us achieve a successful resolution"***

Lim now has a much better understanding of land laws and his rights and responsibilities. This has made him more confident to seek support and help in case other disputes occur in the future.

***"In the future, I want to be a committee member too, in order to help solve my peoples' problems even more effectively"***

When asked how long he hoped the AJC would remain in the community, he answered immediately:

***"Oh! Forever!"***



# NATURAL RESOURCE GOVERNANCE PROGRAM

## Strengthening Partnership towards Participatory and Accountable Governance of Land and Natural Resources in Cambodia

Oxfam believes that fair and sustainable management of land and natural resources is essential to Cambodia's continued development. To make sure the process is transparent and accountable, it is important that all members of society, including the poorest and most disadvantaged, are able to participate in the governance of their own land.

With support and funding from the European Union, Oxfam started the one million euro project in January 2013 targeting 240 villages in Kampong Thom, Preah Vihear, Kratie and Stung Treng provinces. The principal objective was to build stronger partnerships between sub-national authorities and the communities they serve.

The project supported the establishment of Access to Justice Committees for the Poor (AJCs), as well as the provincial-level Cambodia Land and Environment Action Network (CLEAN). These platforms provide a space for communities and civil society groups to engage with local government and an opportunity to share skills and build capacity through training, seminars and international exchanges.

In close partnership with five local NGOs, Oxfam supported information sharing and policy discussion across a network that empowered local citizens to advocate for sustainable natural resource and land governance.

Funded by

EUROPEAN UNION

OXFAM

In partnership with